# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥

នៅក្នុងឆ្នាំ២០១៤នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មក្នុងការផ្តល់សេវាជូនសមាជិក-សមាជិកាព្រឹទ្ធសភា បំពេញមុខងារទាំង៣របស់ខ្លួនទទួលបានលទ្ធផលល្អប្រសើរស្របតាមផែនការសកម្មភាពការងាររបស់គណៈកម្មការនីមួយៗ ។

ភាពជោគជ័យនេះក៏អាស្រ័យដោយការខិតខំបំពេញការងាររបស់ដឹកនាំ និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើការងារអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ពង្រីកពង្រីកបានកាន់តែធំទូលំទូលាយ លើការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងសេវាទ្រទ្រង់ផ្សេងៗទៀតស្របតាមតម្រូវការរបស់ស្ថាប័ន។

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំចាត់ចែងដំណើរការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភាលើការងារនីតិកម្ម ការងារតំណាង និងការងារត្រួតពិនិត្យ បានដោយរលូន ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

បានចាត់ចែងរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២៣លើក ប្រជុំវិសាមញ្ញចំនួន០៣លើក ប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ ចំនួន១៤លើក កសាងឯកសារស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា(២០១៤-២០២៤) កសាងស្តីពីសេចក្តីកំណត់ និងនីតិវិធី អនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៣ ។ រៀបចំពិធីសម្ពោធអគារថ្មី០៣ខ្នង ០៣ជាន់ ជាអំណោយរបស់រាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជូនដល់ព្រឹទ្ធសភា និងរៀបចំតាំងស៊ប់ក្នុងមុខតំណែងជូនមន្ត្រីរាជការប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ប្រជុំពិភាក្សាជាមួយប្រធានគណៈកម្មការនានា និងចូលរួមក្នុងជំនួបសវនាការ ជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងក្នុងពិធីផ្សេងៗព្រមទាំងបានពិនិត្យសម្រេចលើឯកសារ ចំនួន៦៦២៤ច្បាប់ ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (855 23) 211 441, 211 442, 211 443 ទូរសារ៖ (855 23) 211 446, E-mail: oum_sarith@camnet.com.kh

បានអញ្ជើញចូលរួមមហាសន្និបាតលើកទី១៣០ និងលើកទី១៣១ របស់សហភាពអន្តរសភា (IPU) និងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភា(ASGP) នៅប្រទេសស្វីស សិក្ខាសាលាប្រចាំឆ្នាំលើកទី២ ស្តីពីការគ្រប់គ្រងដោយបើកចំហ និងមានតម្លាភាព និងថវិកា នៅទីក្រុងOttawa ប្រទេសកាណាដា កិច្ចប្រជុំរបស់សមាគមអគ្គលេខាធិការសភាពិភពលោក ស្តីពីគោលការណ៍រួមសម្រាប់អភិវឌ្ឍន៍សភា នៅប្រទេសហ្វីលីពីន និងចូលរួមសន្និសីទថ្នាក់ពិភពលោកស្តីពីសភាអេឡិចត្រូនិច នៅសាធារណរដ្ឋកូរ៉េ ។

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការជំនាញ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ចំនួន២១ ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ៖**

-បានចុះបំពេញការងារអមជាមួយសមាជិក-សមាជិកាគណៈកម្មការនានារបស់ព្រឹទ្ធសភា ក្នុងជំនួបសវនាការចំនួន០៤លើក ជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកពន្ធនាគារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល ដើម្បីស្វែងយល់អំពីការអនុវត្តការងារពាក់ព័ន្ធនឹងវិស័យជំនាញរបស់គណៈកម្មការ ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-ទទួលពាក្យបណ្តឹងចំនួន៤៥ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីដោះស្រាយបានចំនួន២៦ករណី ទទួលលិខិតឆ្លើយតបអំពីលទ្ធផលនៃដំណោះស្រាយពាក្យបណ្តឹងបានចំនួន១៣ករណី តម្កល់ទុកមិនចាត់ការចំនួន១៩ករណី ធ្វើលិខិតជំរុញការដោះស្រាយបណ្តឹងទៅក្រសួងស្ថាប័នពាក់ព័ន្ធចំនួន០៣ករណី ទទួលពាក្យបណ្តឹង និងឯកសារជូនជ្រាបពីក្រសួងស្ថាប័នពាក់ព័ន្ធបានចំនួន៨០ករណី ។

-បានសហការរៀបចំវេទិកាសាធារណៈ ចំនួន២០លើក ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋ នៅខេត្តក្រចេះ កណ្តាល ព្រៃវែង ស្វាយរៀង កោះកុង កំពង់ស្ពឺ កំពត ឧត្តរមានជ័យ រាជធានីភ្នំពេញ ស្ទឹងត្រែង ប៉ៃលិន ព្រះវិហារ និងខេត្តត្បូងឃ្មុំ ស្តីពីព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព វិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ ព្រមទាំងការពង្រឹងតួនាទី ភារកិច្ច ការប្រើប្រាស់មូលនិធិថវិកាអភិវឌ្ឍន៍មូលដ្ឋាន ការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ ក្នុងនោះបានលើកឡើងអំពីការឆ្លុះបញ្ចាំងពីដៃគូក្នុងការបើកចំហព័ត៌មានសាធារណៈ និងការដោះស្រាយបញ្ហាសហគមន៍ក្នុងដំណើរឆ្ពោះទៅរកអភិបាលកិច្ចល្អ ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន៨៨៧លើក ដើម្បីចុះជួយប្រជាពលរដ្ឋជួបគ្រោះមហន្តរាយខ្យល់ព្យុះ (បាក់ផ្ទះ) ភ្លើងឆេះ(ផ្ទះ ផ្សារ ) រងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត ជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ចែកប័ណ្ណកម្មសិទ្ធដីធ្លី ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗសរុបចំនួន៩៥៦លើក ។

**៤.សេវាទំនាក់ទំនងខាងព័ត៌មាន៖**

-បានអមដំណើរគណៈប្រតិភូព្រឹទ្ធសភា ទៅបំពេញបេសកកម្មតាមបណ្តាខេត្ត-ក្រុងនានា ចំនួន៣៥លើក ទៅខេត្តតាកែវ កំពត កែប កំពង់ចាម និងខេត្តរតនគិរី ដើម្បីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋ និងស្រាវជ្រាវព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចនៅភូមិភាគទី២ ភូមិភាគទី៥ និងភូមិភាគទី៨ ។

-មន្ត្រីរាជការបានចុះបេសកកម្មចំនួន៤៩លើក ដើម្បីចូលរួមសិក្ខាសាលា ស្រាវជ្រាវ ប្រមូលព័ត៌មានសម្រាប់ត្រៀមរៀបចំវេទិកាជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត រៀបចំជូនក្រុមគ្រូពេទ្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ។

**៥.ការងារអន្តរជាតិ៖**

-បានរៀបចំជំនួបសវនាការជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយគណៈប្រតិភូជាតិអន្តរជាតិ ចំនួន១៦លើក ។

-ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្តកិច្ចសហប្រតិបត្តិការជាមួយប្រទេសស៊ុយអែត និងកិច្ចព្រមព្រៀងជាមួយប្រទេសស្វីស ដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍ និងអនុស្សរណៈនៃការយោគយល់គ្នាពីកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា និងសភាកម្ពុជា ។ ក្រៅពីនេះ មានការចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា និងរដ្ឋសភាបារាំង និងពិធីសម្ពោធអគារវិទ្យាស្ថានសភាកម្ពុជា ។

-ការងារវិទ្យាស្ថានសភាកម្ពុជា មានលទ្ធផលថ្មី (ជំនួយ Sweeden, Swiss, រដ្ឋសភាបារាំង) និងការងារ PBO (សហគមន៍អឺរ៉ុប, ធនាគារពិភពលោក ) ។

-ទទួលដំណើរទស្សនកិច្ចរបស់អនុប្រធានព្រឹទ្ធសភា និងសមាជិកសភាជប៉ុន, គណៈប្រតិភូសភាតំបន់ឥណ្ឌូនេស៊ី ដឹកនាំដោយអនុប្រធានគណៈកម្មការអន្តរសភា, អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន,គណៈប្រតិភូគណៈកម្មការការពារជាតិរុស្ស៊ី ។

-ទទួលជួបជាមួយសមាជិករដ្ឋសភាជប៉ុន គណៈប្រតិភូខុទ្ទកាល័យរដ្ឋសភាឡាវ គណៈប្រតិភូព្រឹទ្ធសភាឥណ្ឌូនេស៊ី អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាថៃ ឯកអគ្គរដ្ឋទូតរុស្ស៊ី កាណាដា និងអាល្លឺម៉ង់ លេខាទី១ និងទីប្រឹក្សាស្ថានទូតជប៉ុន ក្រុមសំណង់ចិន ក្រុមវិនិយោគិនជប៉ុន ។

-បានរៀបចំបែបបទជូនសមាជិក-សមាជិកាព្រឹទ្ធសភាចំនួន៦៥ អញ្ជើញទៅចូលរួមកិច្ចប្រជុំ កិច្ចពិគ្រោះយោបល់ សន្និបាត សន្និសីទ វេទិកា សិក្ខាសាលា ទស្សនកិច្ច បេសកកម្ម និងពិធីផ្សេងៗ នៅប្រទេសចិន ជប៉ុន កូរ៉េ ថៃ ឡាវ វៀតណាម មីយ៉ាន់ម៉ា ស្រីលង្កា ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី កាណាដា បារាំង អាល្លឺម៉ង់ ស្វីស ស៊ុយអែត អ៊ីរ៉ង់ បែលហ្ស៊ិក មិកស៊ិក ហុងគ្រី សាធារណរដ្ឋបេឡារុស្ស និងសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ។

-រៀបចំបែបបទជូនមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅចូលរួមកិច្ចប្រជុំ សន្និបាត សន្និសីទ វេទិកា សិក្ខាសាលា ទស្សនកិច្ច កម្មសិក្សា វគ្គបណ្តុះបណ្តាល និងពិធីផ្សេងៗនៅប្រទេសចិន សិង្ហបុរី កូរ៉េ ជប៉ុន វៀតណាម ថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ឥណ្ឌា ស្វីស បារាំង កាណាដា អាល្លឺម៉ង់ និងរុស្ស៊ី ។

-មន្ត្រីចំនួន០២រូប បានចូលរួមហ្វឹកហ្វឺនការងារស្រាវជ្រាវរយៈពេល០១ឆ្នាំ នៅវិទ្យាស្ថានសភាកម្ពុជា ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៦.ទំនាក់ទំនងសាធារណៈ**

-ទំនាក់ទំនងជាមួយស្ថានីយទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center សាកលវិទ្យាល័យមេគង្គកម្ពុជា សាកលវិទ្យាល័យន័រតុន និងចំរើនពហុបច្ចេកវិទ្យា ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណជន ចូលអានសៀវភៅ ចំនួន៩០៣៧នាក់ និងទទួលដំណើរទស្សនកិច្ចសិក្សារបស់សាស្ត្រាចារ្យ និស្សិតមកពីវិទ្យាស្ថាន**ខេមហ្វឹត** ចំនួន៨៧នាក់ និងសាស្ត្រាចារ្យ និស្សិតនៃសាកលវិទ្យាល័យ Aix Marseille ប្រទេសបារាំងចំនួន១៦នាក់ សាស្ត្រាចារ្យ

និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន៤២នាក់ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងសហគមន៍មកពីខេត្តកំពង់ធំចំនួន៥០នាក់ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងសហគមន៍មកពីខេត្តបន្ទាយមានជ័យចំនួន៧១នាក់ អង្គការអ្នកស្ម័គ្រចិត្តបារាំងចំនួន១៦នាក់ អ្នកគ្រូ លោកគ្រូមកពីខេត្តសៀមរាប ក្រុមអនាគតយុវជនកម្ពុជាអាស៊ានចំនួន២០នាក់ ក្រុមនិស្សិត Summer School នៃសាកលវិទ្យាល័យ Cologne ប្រទេសអាល្លឺម៉ង់ចំនួន៣៥នាក់ និស្សិតកូរ៉េចំនួន១២នាក់ និស្សិតសាកលវិទ្យាល័យអាស៊ីអឺរ៉ុបចំនួន៥០នាក់ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងតំណាងសហគមន៍មកពីខេត្តកំពង់ឆ្នាំងចំនួន៥៥នាក់ និងកងរាជអាវុធហត្ថចំនួន៦៦នាក់ មកទស្សនកិច្ចព្រឹទ្ធសភា ។

**៧.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

*-ការបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេស*

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន៧២វគ្គ (សិក្ខាកាមសរុប៩៨៩នាក់: ប្រុស៦០៩នាក់, ស្រី៣៨០នាក់) ។

-អាហារូបករណ៍ក្នុងប្រទេសចំនួន២៣វគ្គ (សិក្ខាកាមសរុប១០៤នាក់: ប្រុស៦២នាក់, ស្រី៤២នាក់។

*-ការបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស*

-វគ្គបណ្តុះបណ្តាលរយ:ពេលខ្លីចំនួន២២វគ្គ (សិក្ខាកាមសរុប៥៥នាក់: ប្រុស៣៩នាក់,ស្រី ១៦នាក់) នៅប្រទេសស្វីស កាណាដា រុស្ស៊ី ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី ចិន ថៃ និងប្រទេសវៀតណាម ។

-អាហារូបករណ៍រយ:ពេលវែងចំនួន០៨វគ្គ (សិក្ខាកាមសរុប១៥នាក់: ប្រុស១២នាក់, ស្រី០៣នាក់) នៅប្រទេសស្វីស អាល្លឺម៉ង់ អូស្ត្រាលី កូរ៉េ ចិន និងវៀតណាម ។

**៨.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារ០៣ខ្នង ០៣ជាន់ ជាជំនួយរបស់រដ្ឋាភិបាលចិន ។

-រដ្ឋាភិបាលចិនយល់ព្រមសាងសង់អគារ០១ខ្នងជូនព្រឹទ្ធសភា (ការប្តូរលិខិតប្តូរសារជាផ្លូវការ)

-រដ្ឋសភាវៀតណាមបានបញ្ជូនក្រុមអ្នកឯកទេស០៤នាក់ ចុះមកសិក្សាអំពីការបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅក្នុងព្រឹទ្ធសភាកម្ពុជា (ការសិក្សាបច្ចេកទេសជាមួយក្រុមហ៊ុនEZECOM) ។

-ការចុះហត្ថលេខាលើកិច្ចសន្យា ស្តីពីគម្រោងរចនាប្លង់សាងសង់អគារការិយាល័យរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយរបស់រដ្ឋាភិបាលចិនជូនព្រឹទ្ធសភា ដែលនឹងបើកការដ្ឋានសាងសង់នាពេលខាងមុខ។

-បញ្ចប់ការផ្ទេរទីកន្លែង និងការបំពាក់ធនធានមធ្យោបាយបន្ថែមក្នុងក្របខ័ណ្ឌអគ្គលេខាធិការដ្ឋានទាំងមូល ។

-ជានាការរៀបចំអាសនៈក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គ ការបង្កើតលេខាធិការដ្ឋានគណៈកម្មការទី១០ ការិយាល័យសមាជិកព្រឹទ្ធសភា បន្ទប់ប្រជុំគណៈកម្មការទី១០ ការផ្តល់ធនធានមធ្យោបាយ និងការរៀបចំផ្សេងៗស្របតាមការប្រែប្រួលថ្មី ។

-ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណព្រឹទ្ធសភា (ជួសជុលផ្លូវ របង ធ្វើសួនច្បារ តបណ្តាញអគ្គិសនី ទឹក ទូរស័ព្ទ បច្ចេកវិទ្យាព័ត៌មាន) ។

-ការរៀបចំជួសជុលឡើងវិញអតីតអគារសម្ព័ន្ធភាពជាតិឃុំ-សង្កាត់ ធ្វើជាមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន អគារមូលនិធិខ្មែរអភិវឌ្ឍន៍ និងលាបជញ្ជាំងអគារជប៉ុនទី១ និងទី២ អគារអគ្គនាយក/អគ្គនាយករង ការកែសម្រួលប្រព័ន្ធទូរទស្សន៍ខ្សែកាបប្រើប្រាស់ផ្ទៃក្នុងព្រឹទ្ធសភា និងបន្តការសំអាតម៉ាបនៅអគារចិនថ្មី០៣ខ្នង ។

**៩. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែងៈ**

-ចូលរួមពិធីគោរពព្រះវិញ្ញាណក្ខ័ន្ធ និងដង្ហែព្រះបរមអដ្ឋិ **ព្រះករុណា ព្រះបាទ សម្តេចព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះករុណាព្រះបរមរតនកោដ្ឋ ។

-ចូលរួមទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនៈកោដ្ឋ ។

-ចូលរួមក្នុងព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិខួបលើកទី១០ របស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

-ចូលរួមពិធីដាក់កម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបរមរតនកោដ្ឋ និងពិធីខួបអនុស្សាវរីយលើកទី៦១ នៃទិវាបុណ្យឯករាជ្យជាតិ ០៩ វិច្ឆិកា ។

-ដំណើរការបេឡាសោធន៍និវត្តក្រោមការដឹកនាំរបស់គណៈកម្មការថ្មី ។

-បានបញ្ចប់ការងារប្រកាសទ្រព្យសម្បត្តិដើមឆ្នាំ២០១៤ (១០៦នាក់) ។

-បញ្ចប់នីតិវិធីលទ្ធកម្ម (ឯកសណ្ឋាន ប្រេងឥន្ធនៈ សម្ភារការិយាល័យ សម្ភារសំអាតអនាម័យ និងការបោះពុម្ព) កាត់ឯកសណ្ឋានជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

-បញ្ចប់ការរៀបចំយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល (២០១៥-២០១៧) និងឯកសារពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

-រៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភា ឆមាសទី១ ឆ្នាំ២០១៤ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

-ការធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពីការអនុវត្តថវិកាឆ្នាំ២០១៨ និងកសាងគោលការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៩ ។

-ធ្វើកាតបើកប្រាក់បៀវត្សATMថ្មី ជូនអតីតសមាជិកព្រឹទ្ធសភា ទីប្រឹក្សាជំនួយការផ្ទាល់ ជំនួយការអមគណៈកម្មការជំនាញ អ្នកបើកបរ មន្ត្រីក្របខ័ណ្ឌ មន្ត្រីចូលនិវត្តន៍ និងបុគ្គលិកជាប់កិច្ចសន្យាចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅធនាគារACLEDA (ជំនួសធនាគារANZ ) ។

-ប្រជុំស្តីពីការសិក្សាព្រះរាជក្រឹត្យកំណត់មុខតំណែង ក្របខ័ណ្ឌ ឋានន្តរសក្តិ ថ្នាក់ និងសន្ទស្សន៍បៀវត្ស ព្រមទាំងរៀបចំសមាហរណកម្មមន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទៅក្នុងក្របខ័ណ្ឌ ឋានន្តរសក្តិ ថ្នាក់ និងសន្ទស្សន៍បៀវត្សថ្មី ។

-បំពាក់បរិក្ខារបច្ចេកវិទ្យា និងជំរុញអនុវត្តការប្រើប្រាស់បច្ចេកវិទ្យាក្នុងការងារ ។

-គិតគូរអភិវឌ្ឍន៍Facebook របស់ព្រឹទ្ធសភា និងទំនាក់ទំនងផ្ទៃក្នុងតាម Line ។

-ពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អនុវត្តវិន័យ និងរបបរាយការណ៍វត្តមានទៀងទាត់ប្រាកដប្រជាតាមonline ។

-ធ្វើសេចក្តីសម្រេចស្តីពីគោលនយោបាយចំពោះអ្នករាជការ ដែលបានសុំលាឈប់ពីក្របខ័ណ្ឌអ្នករាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

-ធ្វើរបាយការណ៍ចន្លោះសម័យប្រជុំ របាយការណ៍តាមវិស័យ លើកទី៤ លើកទី៥ និងលើកទី៦ នីតិកាលទី៣ ព្រឹទ្ធសភា ។

-វាយតម្លៃការអនុវត្តផែនការប្រតិបត្តិសម្រាប់ត្រីមាសទី១ និងឆមាសទី២ ឆ្នាំ២០១៨ ។

-ធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការកែសម្រួលក្បាលម៉ាស៊ីនព្រឹទ្ធសភា ក្នុងរង្វង់គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ក្រុមសមាជិកព្រឹទ្ធសភា ក្រុមភូមិភាគ ក្រុមមិត្តភាព៥ក្រុម, ក្រុមAIPA, IPU, APF, CLV ក្រុមសមាជិកាព្រឹទ្ធសភា ។

-រៀបចំដំណើរការប្រឡងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ និងរៀបចំសេចក្តីសម្រេចតាំងស៊ប់ក្នុងមុខតំណែងជូនមន្ត្រីរាជការចំនួន១០៧រូប ។

-ការរៀបចំប្រទីបព្រឹទ្ធសភា ក្នុងពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ ។

-ការងារចាត់តាំងពាក់ព័ន្ធអគ្គលេខាធិការរងថ្មី និងបុគ្គលិកបម្រើការនៅខុទ្ទកាល័យ ។

-ការងារបុគ្គលិកៈ ការចូលនិវត្ត ការសម្រួលភារកិច្ចក្នុងក្បាលម៉ាស៊ីន ការផ្ទេរក្នុង/ក្រៅស្ថាប័ន ។

-ការបន្តកិច្ចសន្យាដល់អ្នកជាប់កិច្ចសន្យាតាមអង្គភាពនានា ។

-បានបញ្ចប់វាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការប្រតិបត្តិ ត្រីមាស ឆមាស ចតុមាស និងប្រចាំឆ្នាំ២០១៤ បច្ចុប្បន្នភាពផែនការប្រតិបត្តិឆ្នាំ២០១៥ និងការធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រ សម្រាប់ឆ្នាំ២០១៣-២០១៨ ។

-ការងារសារពើភ័ណ្ឌទ្រព្យសម្បត្តិ ធនធានមនុស្ស ជំនាញ និងសំណុំឯកសារឆ្នាំ២០១៤ ការកសាងផែនការតម្រូវការជំនាញឆ្នាំ២០១៥ ។

-បានរៀបចំទិវាមនុស្សចាស់ជូនអតីតមន្ត្រីចូលនិវត្តន៍ និងមន្ត្រីជិតចូលនិវត្តន៍នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

-បានបោះពុម្ពបទបញ្ជាផ្ទៃក្នុង កម្រងសេចក្តីសម្រេច និងសៀវភៅលឿង ។

-ធ្វើបច្ចុប្បន្នភាពសៀវភៅរដ្ឋធម្មនុញ្ញ ។

-បានចាត់ចែងបោះពុម្ពក្របខ័ណ្ឌយុទ្ធសាស្ត្រ១០ឆ្នាំ សំរាប់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងការបកប្រែជាភាសាអង់គ្លេស/បារាំង

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន១២៦លើក ។

-ថតចម្លងឯកសារចំនួន១៤៩៦សំណើ ចងក្រងឯកសារជាសៀវភៅចំនួន៣២៦ក្បាល ដោះស្រាយសំណើថវិកា ចំនួន៣៣៧៤សំណើ និងសម្ភារចំនួន៦០៥សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន១២៤២លើក ។

-ទទួលសម្ភារខូច ម៉ាស៊ីនហ្វូតូកូពី UPS, Keyboard, CPU, Monitor, Printer កៅអីវិលតូចធំ និងម៉ូតូចំនួន៣២គ្រឿង ប្រគល់ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនស្វាយ កុំព្យូទ័រ ទូរទស្សន៍ ក្បាលមេក្រូ ធុងបាស ទូទឹកកក ទូរស័ព្ទលើតុ UPS តុប្រជុំ តុការិយាល័យ ទូ កៅអី សាឡុង ក្តារខៀន ចំនួន១៥២៨គ្រឿង និងទឹកថ្នាំម៉ាស៊ីនហ្វូតូកូពីចំនួន២៥ដប ។ បំពាក់ទូរទស្សន៍ តបណ្តាញខ្សែកាបទូរទស្សន៍ ជើងស្វាយ នាឡិកា កង្ហារបឺត ប្តូរទីតាំងទូរទស្សន៍ ចំនួន៧៣គ្រឿង និងបិទលេខកូដកៅអីតុដែក ទូទឹកកក ទូដាក់ឯកសារ ម៉ាស៊ីនបញ្ចាំងស្លាយ កុំព្យូទ័រ ម៉ាស៊ីនព្រីនធ័រ ក្បាលមេក្រូ IPad UPS និងកាសត្រចៀក ចំនួន៣២៣គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ ទូរស័ព្ទ ទូទឹកកក បន្ទប់ទឹក តុ កៅអី ប្តូរអំពូល ព្រី កុងតាក់ ឌីសង់ទ័រ អូតូទ្វារ ដៃទ្វារអ៊ីណុក សោទ្វារ កញ្ចក់ទ្វារ កញ្ចក់តុ សោតុ ទូ ចំនួន១២២៣គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្ម

វិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៤៨៩គ្រឿង និងបានUpload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៦៨៥ប្រធានបទ ។

**II.ទិសដៅការងារ ឆ្នាំ២០១៥**

-ការកិច្ចស្នូលគឺចូលរួមផ្តល់សេវា និងផលិតផលដើម្បីសម្រេចឲ្យបាននូវមុខងារទាំង៣ សហប្រតិបត្តិការអន្តរជាតិ ការអភិវឌ្ឍស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្សតាមមុខសញ្ញា និងវិស័យរៀងៗខ្លួន ។

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គ លើកទី៦ ព្រឹទ្ធសភា ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ/ ព័ត៌មាន៖**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

**៤.ការងារអន្តរជាតិ៖**

-ត្រៀមចូលរួមសហការរៀបចំកិច្ចប្រជុំមហាសន្និបាតសភាអាស៊ី(APA) នៅខែធ្នូ ឆ្នាំ២០១៥ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ។

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា ។

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស រួមទាំងអគ្គលេខាធិការដ្ឋាន។

-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា និងដៃគូនានា ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-ជំរុញលើកកម្ពស់ចំណេះដឹង ការបើកវគ្គសិក្សាជំនាញ ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

**៦.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-អនុវត្តន៍គម្រោងសាងសង់អគារថ្មីជាមួយទីប្រឹក្សាពាណិជ្ជកម្មចិន ។

(ការត្រៀមសម្អាតការដ្ឋានសាងសង់ទាំងនៅលើដី និងក្រោមដី) ។

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយចិន កូរ៉េ ជប៉ុន ឥណ្ឌា និងវៀតណាម និងការកសាងមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន។

**៧.ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ចូលរួមចាត់ចែងពិធីបុណ្យជាតិ អន្តរជាតិប្រចាំឆ្នាំ ។

-គោលការណ៍អនុវត្តថវិកាឆ្នាំ២០១៩ និងនីតិវិធីអនុវត្តគោលការណ៍អង្គភាពថវិកា និងការចំណាយតាមកម្មវិធី នីតិវិធី និងបែបបទលទ្ធកម្មសាធារណៈឆ្នាំ២០១៩ ។

-រាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ការបែងចែកកញ្ចប់ថវិកាឆ្នាំ២០១៩ និងការទូទាត់ថវិកាចំណាយឆ្នាំ២០១៨ ។

-បន្តពង្រឹងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងរដ្ឋបាលសាធារណៈ ។

-ត្រៀមអនុវត្តប្រព័ន្ធក្របខ័ណ្ឌ និងប្រាក់បៀវត្សថ្មីរបស់មន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

-ត្រៀមរៀបចំបែបបទ និងពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា ។

-រៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម និងអគារផ្សេងៗទៀត ។ ធ្វើបច្ចុប្បន្នភាព និងថែរក្សាឯកសារសហប្រតិបត្តិការជាមួយដៃគូ ។

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីបង្កើនសមត្ថភាព ផ្តល់សេវាព័ត៌មានចាំបាច់ និងជាមូលដ្ឋាន (នាយកដ្ឋានស្រាវជ្រាវទូទៅ នាយកដ្ឋានស្រាវជ្រាវកិច្ចការសភា) ។

-ការងារគ្រប់គ្រង និងជំរឿនមន្ត្រីរាជការ ធនធាន មធ្យោបាយ និងទ្រព្យសម្បត្តិ ជំរឿនប្រព័ន្ធអគ្គិសនី លូទឹក ទឹក ផ្លូវថ្នល់ ចិញ្ចើមថ្នល់ ។

-ចាត់ចែងការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីរាជការ និងសមាជិកព្រឹទ្ធសភាឲ្យបានទាន់ពេលវេលា។ ប្រធាននាយកដ្ឋាននីមួយៗត្រូវទទួលខុសត្រូវដោយផ្ទាល់លើបញ្ហាមានមន្ត្រីខ្មោចក្នុងនាយកដ្ឋានរបស់ខ្លួន។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងឆ្នាំ២០១៨នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ និងបន្តសម័យប្រជុំពេញអង្គលើកទី៥ លើកទី៦ ដោយបានពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន២០ និងបានបន្តកសាងសេចក្តីព្រាងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃ

បទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពស្ថាប័ន(២០១៤-២០២៤) និងទស្សនវិស័យនៃដំណើរទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា(២០១៤-២០២៤) ។ ជាពិសេសការរៀបចំទីកន្លែងសម្រាប់ជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ និងគណបក្ស សម រង្ស៊ី ដែលបានប្រព្រឹត្តទៅដោយជោគជ័យ ។ ការអនុវត្តនូវដំណោះស្រាយនយោបាយនឹងបង្កើតឡើងនូវការប្រែប្រួលថ្មី ដែលពាក់ព័ន្ធនឹងគណៈកម្មការនានា និងក្នុងអគ្គលេខាធិការដ្ឋានរបស់ព្រឹទ្ធសភាផងដែរ ។ នោះគឺបន្ទុកថ្មីបន្ថែមដែលឲ្យទិដ្ឋភាពការងារខុសឆ្ងាយពីនីតិកាលទី១ និងនីតិកាលទី២ ដែលមានត្រឹមតែ៩គណៈកម្មការ និងអគ្គលេខាធិការរងតែម្នាក់ ។

ក្នុងកម្មុងនេះ ថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់លើការងារមូលដ្ឋានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីលើកកម្ពស់មុខងារតំណាង មុខងារត្រួតពិនិត្យ និងមុខងារនីតិកម្ម ។ សមាជិក-សមាជិកាព្រឹទ្ធសភា តាមរយៈយន្តការ(គណៈកម្មការ ក្រុមភូមិភាគ ក្រុមសមាជិកា) បានធ្វើចលនាដោយសកម្ម ដើម្បីស្វែងរកព័ត៌មាន អនុវត្តការងារតំណាង និងស្វែងយល់អំពីការអនុវត្តច្បាប់នានា ជាពិសេសការរៀបចំវេទិកាតាមភូមិភាគ ។ បានបញ្ចប់ការសាងសង់ ព្រមទាំងរៀបចំពិធីសម្ពោធអគារ០៣ខ្នង ០៣ជាន់ និងការផ្លាស់ប្តូរកន្លែងធ្វើការរបស់គណៈកម្មការ និងនាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋាន។

ចំពោះការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ យើងទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់ដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្តកិច្ចសហប្រតិបត្តិការជាមួយប្រទេសស៊ុយអែត និងជាមួយប្រទេសស្វីស ដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍ និងអនុស្សរណៈនៃការយោគយល់គ្នាពីកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា និងសភាកម្ពុជា ។ ក្រៅពីនេះ មានការចុះហត្ថលេខាសហប្រតិបត្តិការជាមួយរដ្ឋសភាបារាំង និងការគាំទ្រពីGIZ, CIM និងSES មានរហូតដល់ចុងឆ្នាំ២០១៧ ។ KAS នៅតែសកម្មគាំទ្រកិច្ចសហប្រតិបត្តិការជាមួយព្រឹទ្ធសភា ជាពិសេសក្នុងការដ្ឋានសាងសង់កសាងនីតិវិធីអនុវត្តបទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា ។ រដ្ឋសភាកូរ៉េ គឺជាច្រកថ្មីនៃការអភិវឌ្ឍ និងបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន ។ដ

បញ្ចប់កសាងថវិកាឆ្នាំ២០១៥ តាមយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល (២០១៥-២០១៧) និងឯកសារក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍស្ថាប័ន និងទស្សនវិស័យអភិវឌ្ឍន៍អគ្គលេខាធិការដ្ឋានឆ្នាំ២០១៤-២០២៤ ។

ដំណើរការសុខដុមកម្ម និងប្រក្រតីកម្មការងារ និងការកសាងបរិយាកាសការងារល្អប្រសើរ នៅតែជាអាទិភាពខ្ពស់ក្នុងបរិបទសហគមន៍ អាស៊ាន និងខួប១៩ឆ្នាំរបស់ព្រឹទ្ធសភា ។ ទីកន្លែងធ្វើការ និងមធ្យោបាយការងារត្រូវបានពង្រីក និងបំពាក់បន្ថែមក្នុងបរិមាណ និងគុណភាពមួយថ្មី និងទូលាយជាងមុន ។ ការប្រឈមទាមទារឲ្យបង្ហាញនូវប្រសិទ្ធភាពថ្មី ប្រសិទ្ធផលថ្មី និងគុណភាពថ្មី ក្នុងការងារ ។ ត្រូវចងចាំអំពីការសន្សំសំចៃឲ្យបានខ្ពស់បំផុត ។

ជំហានទៅមុខត្រូវអនុវត្តដោយសកម្ម ។ ការប្រឈមថ្មីៗតែងកើតមានជាដរាប ។ មិនថាឧបសគ្គ និងការលំបាកប៉ុណ្ណាក្តី ត្រូវសំរួចឆន្ទៈ សាមគ្គីរួបរួមគ្នាជំនះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

«ទាំងអស់គ្នាដើម្បីស្ថាប័ន ហើយស្ថាប័នដើម្បីទាំងអស់គ្នា» ។/៣

ភ្នំពេញ,ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩

**អគ្គលេខាធិការ**